**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**អគ្គលេខាធិការដ្ឋាន**

លេខៈ ០៦០/១៨ ....... អ.ជ.ប.គ.ញ

ថ្ងៃ ពុធ ៨កើត ខែបឋមាសាឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែឧសភា និងទិសដៅការងារ ខែមិថុនា ឆ្នាំ២០១៨

(២៦/០៤/២០១៨ - ២៥/០៥/២០១៨)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមរយៈការអនុវត្តផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ការចូលរួមអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ក៏ដូចជាផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ (០១ ខែមករា - ៣១ ខែធ្នូ ឆ្នាំ២០១៨) របស់រាជរដ្ឋាភិបាល និងផែនការសកម្មភាពអនុវត្តទិសដៅការងារ ដែលបានដាក់ចេញកាលពីខែមេសាកន្លងទៅ យើងបានកត់សម្គាល់ពីសភាពការណ៍គ្រឿងញៀន និងអនុវត្តការងារនៅក្នុងខែឧសភានេះ ទទួលបានលទ្ធផលដូចតទៅ ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែឧសភានេះ ការចរាចរ ដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ ពីតំបន់ត្រីកោណមាស ឆ្លងកាត់ប្រទេសឡាវចូលមកកម្ពុជា តាមបណ្តាច្រកនៃខេត្តភាគឦសានប្រទេស នៅតែបន្តសកម្មភាពគួរកត់សម្គាល់នៅឡើយ ដែលក្នុងនោះ កម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀនបង្ក្រាបបាន ៥ ករណី និងចាប់យកមេតំហ្វេតាមីន ICE - WY ប្រមាណជាង ១ គីឡូក្រាម ។

ដោយឡែក ការផ្ញើតាមបញ្ញើប្រៃសណីយ៍បានកើតឡើង ២ ករណី ត្រូវបានកម្លាំងរបស់មន្ទីរប្រឆាំងគ្រឿងញៀនសហការជាមួយមន្ត្រីប៉ុស្តិ៍ប្រៃសណីយ៍ និងមន្ត្រីគយនិងរដ្ឋាករកម្ពុជា ចាប់យកកញ្ចប់បញ្ញើប្រៃសណីយ៍ មានបង្កប់គ្រឿងញៀន ផ្ញើពីប្រទេសហូឡង់ និងប្រទេសប៊ែលហ្សិក ដោយបានឃាត់ខ្លួនជនសង្ស័យ ៣ នាក់ (ជនជាតិនីហ្សេរីយ៉ា១នាក់) ។ ករណីផ្ញើតាមបញ្ញើប្រៃសណីយ៍ខាងលើនេះ សមត្ថកិច្ចបានចាប់យក អ៊ិចស្តាស៊ី ប្រមាណជាង ៣ គីឡូក្រាម ។ ជាការកត់សម្គាល់ការពីខែមេសាកន្លងទៅ សមត្ថកិច្ចមន្ទីរប្រឆាំងគ្រឿងញៀន និងសាខាគយនិងរដ្ឋាករប្រៃសណីយ៍ បានរកឃើញការផ្ញើរតាមបញ្ញើរប្រៃសណីយ៍ នូវស្លឹករុក្ខជាតិក្រៀម khat (ខាត) ដែលជារុក្ខជាតិមានផ្ទុកនូវសារធាតុញៀនឈ្មោះ Cathinone (កាទីណូន)និង Cathine (កាទីន) ចេញពីកម្ពុជាទៅកាន់សហរដ្ឋអាមេរិក ។ រុក្ខជាតិ khat (ខាត) មានប្រភពមកពីទ្វីបអាហ្វ្រិក និងអារ៉ាប់ ហើយនៅប្រទេសមួយចំនួនបានចាត់ទុកជារុក្ខជាតិញៀនដោយបានដាក់បញ្ចូលទៅក្នុងច្បាប់ត្រួតពិនិត្យគ្រឿងញៀន ។ សរុបរួម ៧ ករណីខាងលើ សមត្ថកិច្ចបានចាប់យក មេតំហ្វេតាមីន ICE - WY និង អ៊ិចស្តាស៊ី ប្រមាណជាង ៤ គីឡូក្រាម ស្មើនឹង ៨០% នៃចំនួនគ្រឿងញៀនសរុប ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

## II. អំពីការងារដឹកនាំ ៖

### ១. ការងារដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បានចេញ ព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន លេខ នស/រកត/**០៥១៨**/៥៩៧ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ ។

### ២. ការដឹកនាំរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ប្រធាន អ.ជ.ប.គ.ញ. បានបន្តដឹកនាំ និងណែនាំលើការងារសំខាន់ៗ ជាពិសេសការងារពាក់ព័ន្ធនឹងការអនុវត្តផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងការចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ ដូចខាង ក្រោម ៖

២.១. **ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវបន្តជំរុញការអនុវត្តវិធានការផ្សព្វផ្សាយអប់រំដល់សិស្ស-និស្សិត កម្មករ-ពលករ ជនចំណាកស្រុក តាមគ្រប់រូបភាព (ការផ្សព្វផ្សាយតាមបណ្តាញព័ត៌មាន ប្រព័ន្ធទូរស័ព្ទ ការបិទតាំងខ្លឹមសារអប់រំតាមគោលដៅទេសចរណ៍) និងបន្តការរៀបចំវេទិកាតុមូល វេទិកាសាធារណៈ វេទិកាជួបជាមួយវិស័យឯកជន ព្រមទាំងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត ។

២.២. **ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** ត្រូវបន្តពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរដ្ឋនិងឯកជនឱ្យមាននិរន្តរភាព ដើម្បី ទទួលជនរងគ្រោះដែលអង្គភាពអនុវត្តន៍ច្បាប់ ស្ថាប័នតុលាការបញ្ជូនទៅទទួលសេវាព្យាបាល, ត្រូវពង្រឹងពង្រីក សេវាព្យាបាលដោយផ្អែកលើសហគមន៍តាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកបន្ថែមទៀត ។ ជាមួយនេះ ត្រូវពិនិត្យស្នើសុំមូលនិធិសមធម៌ដល់អ្នកញៀនគ្រឿងញៀន ឱ្យបានទទួលសេវាពិនិត្យ និងព្យាបាលភាពញៀនគ្រឿងញៀន ដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ព្រមទាំងពង្រឹងសេវាគាំទ្រផ្សេងៗទៀត សំដៅ លើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍ ដើម្បីកាត់បន្ថយការលាប់ទៅប្រើគ្រឿងញៀនឡើងវិញ និងបន្តការងារសាងសង់មណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឲ្យបានឆាប់រហ័ស ។

២.៣. **ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមរយៈការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀន និងសារធាតុគីមីផ្សំ តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ **(CBT)**, តាមប្រព័ន្ធអេឡិចត្រូនិក (e-Learning), និងការបណ្តុះបណ្តាលជំនាញផ្សេងៗទៀតដល់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន **(BLO)**, មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងក្រុមជនបង្គោល នៃកងយោធពលខេមរភូមិន្ទ ។ ទន្ទឹមនេះ ត្រូវពន្លឿននីតិវិធីក្នុងការជម្រះក្តីពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ជាពិសេស រឿងក្តីដែលពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិឱ្យបានឆាប់ ដើម្បីគណៈកម្មការ ការតាមដានការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ បន្តនីតិវិធីហិរញ្ញវត្ថុ ឱ្យទាន់ពេលវេលា ចៀសវាងការខូចខាត ធ្លាក់ចុះតម្លៃ ឬឈានដល់បាត់បង់តម្លៃសេដ្ឋកិច្ចទាំងស្រុងនៃទ្រព្យសម្បត្តិទាំងនោះ ។

២.៤. **ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** បន្តជំរុញការងាររបស់ក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំឱ្យបានទៀងទាត់ និងការងាររបស់ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។ ជា

មួយនេះ ត្រូវសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម បន្តការរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិ ស្តីពីការបិទស្លាកសញ្ញាការទុកដាក់ការវេចខ្ចប់នូវសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

២.៥. **កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** បន្តអនុវត្តនូវរាល់កិច្ចការ ដែលបានព្រមព្រៀងគ្នាកន្លងមកជាមួយភាគីថៃ ឡាវ និង វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនព្រមទាំងការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់ប្រទេសកម្ពុជា ថៃ និងឡាវ ជាពិសេសអនុវត្តយន្តការភូមិ ស គ្មានគ្រឿងញៀន នៅតាមព្រំដែនដែលភាគីកម្ពុជា ឡាវ ថៃ បានឯកភាពគ្នាកន្លងមករួមទាំងកិច្ចអន្តរាគមន៍នានាដែលមានលក្ខណៈពហុវិស័យ ក្នុងការពង្រឹង ពង្រីកការិយាល័យ ទំនាក់ទំនងព្រំដែន **(BLO)** តាមបណ្តោយព្រំដែន កម្ពុជា-ឡាវ, កម្ពុជា-ថៃ ។

២.៦. **កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា ៖** បន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី អង្គការ **UNODC** បណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ ។

២.៧. **ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវបន្តការកែសម្រួលមាត្រាមួយចំនួននៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិ ដែលជាផលបានមកពីបទល្មើសគ្រឿងញៀន ។ ជាមួយនេះ ត្រូវធ្វើការណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅគ្រប់ឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាពសម្រាប់ការ ព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

ក្រៅពីការងារដឹកនាំ និងណែនាំខាងលើ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានជួបសំណេះសំណាលនិងបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន ដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋនៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ចំនួន ២៦.៨៩៤ នាក់ ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឆ្លើយតបទៅនឹងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ និងទិសដៅការងារ ដលបានដាក់ចេញកាលពីខែមេសា ឆ្នាំ២០១៨ និងតាមការណែនាំរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

#### ១.១. ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

- សហការជាមួយស្ថានីយទូរទស្សន៍បាយ័ន រៀបចំកម្មវិធីជជែកពិភាក្សាតុមូល ក្រោមប្រធានបទ "ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់តាមតំបន់ព្រំដែន" ដែលមានវាគ្មិនមកពីតំណាងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ និងខេត្តស្វាយរៀង
- សហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី. អញ្ជើញតំណាងក្រសួងពាណិជ្ជកម្ម ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងក្រសួងការពារជាតិ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច "ក្រោមប្រធានបទការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ ឆ្នាំ២០១៨"
- សហការជាមួយស្ថានីយវិទ្យុFm ជាតិ៩៦Mhz បានផ្តល់បទសម្ភាសន៍ពីប៉ះពាល់និងគ្រោះថ្នាក់នៃការប្រើប្រាស់និងដំណោះស្រាយបញ្ហាគ្រឿងញៀន

- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែមេសា ឆ្នាំ២០១៨ មានការចូលអានចំនួន **៣៦.៤៩៥ ដង**

- ផ្សព្វផ្សាយឃ្លីបវីដេអូខ្លីស្តីពីបញ្ហាគ្រឿងញៀន និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក តាមបណ្តាញទំនាក់ទំនងសង្គម Page Facebook របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**១.២. ការងារអប់រំតាមសហគមន៍**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន មានមហាជនទៅទទួលសារសារអប់រំចំនួន **១៣៤.១៥៧** នាក់ ។

ក្នុងនោះ ការងារដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានសហការអនុវត្តមាន ៖

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមធ្វើបទឧទ្ទេសនាមអំពីផលប៉ះពាល នៃគ្រឿង ញៀន ដែលរៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ កាលពីថ្ងៃទី២៤-២៥ ខែឧសភា ឆ្នាំ២០១៨ នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលមានអ្នកចូលរួម ៦៥០ នាក់

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងសហការី ១រូប ចូលរួមធ្វើបទបង្ហាញអំពីគ្រោះថ្នាក់ នៃការប្រើប្រាស់គ្រឿងញៀន នៅក្នុងវគ្គផ្សព្វផ្សាយអប់រំពីការប្រើប្រាស់ គ្រឿងញៀនខុសច្បាប់ និងសុវត្ថិភាពចរាចរណ៍ផ្លូវគោក ជូនដល់សិស្សានុសិស្សតាម វិទ្យាល័យ ដែលរៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា កាលពីថ្ងៃទី២៦-២៨ ខែមេសា ឆ្នាំ ២០១៨ នៅខេត្តព្រះសីហនុ

- ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមធ្វើបង្ហាញស្តីពីការចូលរួមទាំងអស់គ្នាដើម្បីជីវិត និងសហគមន៍យើងគ្មានគ្រឿងញៀន ដែល រៀបចំដោយក្រសួងធម្មការ និងសាសនា កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨ ខេត្តកំពង់ចាម

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមជាគណៈមេប្រយោគដាក់ពិន្ទុ ក្នុងវេទិកាពិភាក្សាជជែកដេញដោលតស្ស៊ូមតិ នៅក្នុងគម្រោង THEPERSPECTIVES CAMBODIA រដូវកាលទី២ ក្រោមប្រធានបទ "អាជ្ញាធរមានសមត្ថកិច្ច ដើរ តួនាទីដ៏ចម្បងក្នុងការទប់ស្កាត់ការប្រើប្រាស់ និងជួញដូរគ្រឿងញៀននៅកម្ពុជា " កាលពីថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ២០១៨ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ

- ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២រូប ចូលរួមធ្វើបទឧទ្ទេសនាម អំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ដែលរៀបចំដោយ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច កាលពីថ្ងៃទី០៨-១០ ខែឧសភា ឆ្នាំ ២០១៨ នៅស្រុកគាស់ក្រឡ ស្រុករុក្ខគីរី ខេត្តបាត់ដំបង និងក្រុងសិរីសោភ័ណ ខេត្តបន្ទាយមាន ជ័យ ដែលមានអ្នកចូលរួម ១.១៧៤ នាក់

- ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមធ្វើបទបង្ហាញពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន ដែលរៀបចំដោយក្រសួងទេស- ចរណ៍ កាលពីថ្ងៃទី២៤-២៥ ខែឧសភា ឆ្នាំ២០១៨ នៅខេត្តមណ្ឌលគិរី

- ក្រសួងសាធារណការនិងដឹកជញ្ជូន បានស្នើក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ឱ្យណែនាំអ្នកបើកបរ កុំឱ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងស្នើឱ្យមានការបិទខិតប័ណ្ណផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមរថយន្ត

- ក្រុមហ៊ុន HD&S Group Co.,LTD បានបញ្ជ្រាបខ្លឹមសារពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនក្នុងកម្មវិធីប្រគំតន្ត្រីទេសចរណ៍ ដែលមានអ្នកចូលរួម ៦៣.១០០ នាក់ ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ ចំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាយោបល់មជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាប្រឆាំងមេរោគអេដស៍អាស៊ីអាគ្នេយ៍ (SEA-HATTC) ដែលរៀបចំដោយមជ្ឈមណ្ឌលប្រព័ន្ធផ្ទេរបច្ចេកវិទ្យានៃការញៀន (ATTC) កាលពីថ្ងៃទី០៨-១៦ ខែឧសភា ឆ្នាំ២០១៨ នៃខេត្តឈៀងម៉ៃ ប្រទេសថៃ

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាល និងប្រមូលទិន្នន័យ ស្តីពីការអង្កេតជាតិការចំណាយប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៦ សម្រាប់ឆ្នាំ២០១៦ និង២០១៧ ដែលរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨

- ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២រូប ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលស្តីពីការអង្កេតស្រាវជ្រាវចំណេះដឹងពីជំងឺអេដស៍ ការប្រព្រឹត្តផ្លូវភេទ និងរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ មេរោគស្វាយ និងការប៉ាន់ស្មានចំនួនអ្នកប្រើប្រាស់គ្រឿងញៀន នៅប្រទេសកម្ពុជា ឆ្នាំ២០១៧ ដែលរៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ

- បន្តការគាំទ្រចំពោះអង្គការដៃគូ ដែលបាននិងកំពុងអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដើម្បីកាត់បន្ថយការឆ្លងមេរោគអេសដ៍ និងរោគឆ្លងតាមឈាមផ្សេងៗទៀត

- បន្តផ្តល់សេវាព្យាបាលដោយឱសថជំនួសមេតាដូន ដល់អ្នកញៀនហេរ៉ូអ៊ីន (ពពួកអាភៀន) ។

### ២.២. ការព្យាបាល និងស្តារនីតសម្បទា

- បានជំរុញឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ពង្រឹងឬបង្កើតគណៈកម្មការសម្របសម្រួលការព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមឃុំ-សង្កាត់ ដើម្បីជំរុញអ្នកប្រើប្រាស់និងញៀនគ្រឿងញៀនឱ្យទៅទទួលយកការព្យាបាល នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្ត នៅតាមសហគមន៍

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានរៀបចំកិច្ចប្រជុំឆ្លងគោលការណ៍ណែនាំប្រតិបត្តិ ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ កាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានបន្តដំណើរការនៃការសាងសង់អគាររដ្ឋបាល អគារមន្ទីរពេទ្យ ឃ្លាំង បន្ទប់ អគ្គិសនី បន្ទប់ចម្រោះទឹកស្អាត និងកំពុងសាងសង់អគារស្នាក់នៅ និងរបងមណ្ឌល នៃមជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយ ស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នក ញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

- បានស្នើសុំទៅក្រសួងយុត្តិធម៌ ជួយផ្សព្វផ្សាយ និងបញ្ជូននូវបញ្ជី សេវាសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនឆ្នាំ២០១៧ ទៅដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត

- បានស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ជួយផ្សព្វផ្សាយ និងបញ្ជូននូវបញ្ជីសេវាសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនឆ្នាំ២០១៧ ទៅដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់

- បន្តការស្នើសុំទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជួយផ្សព្វផ្សាយ និងបញ្ជូននូវបញ្ជីសេវាសុខភាព ផ្លូវចិត្ត និងការបំពានគ្រឿងញៀនឆ្នាំ២០១៧ ទៅដល់ព្រះរាជអាជ្ញារាជធានី-ខេត្ត ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

- ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២រូប ចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលគ្រូបង្គោល ស្ដីពីការអនុវត្តគោលការណ៍ និងការត្រួតពិនិត្យឯកសារពាក់ព័ន្ធ សម្រាប់មន្ត្រីបម្រើការងារនៅតាមច្រកទ្វារព្រំដែន ដែលរៀបចំដោយផ្នែកការពារព្រំដែន និងអន្តោប្រវេសន៍នៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា កាលពីថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានបើកវគ្គបណ្ដុះបណ្ដាលស្ដីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) វគ្គទី២ នៅថ្ងៃទី០៧-១១ ខែឧសភា ឆ្នាំ២០១៨ និងវគ្គទី៣ នៅថ្ងៃទី២១-២៥ ខែឧសភា ឆ្នាំ២០១៨ នៅអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានអ្នកចូលរួម ២៤នាក់ ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀនសរុប **៥៣៣ ករណី** (រួមទាំងបទល្មើសប្រើប្រាស់) ប្រៀបធៀបខែមេសា មាន **៥៣៥ ករណី** មានការថយចុះ ២ករណី ស្មើនឹង ០.៣៧% ។

- **ជនសង្ស័យឃាត់ខ្លួន ៩៨៧នាក់ ស្រី ៩៦នាក់** (រួមទាំងជនប្រើប្រាស់) ប្រៀបធៀបខែមេសា មាន **១.០១៧នាក់** មានការថយចុះ ៣០នាក់ ស្មើនឹង ២.៩៤% ។

**ជនសង្ស័យទាំងអស់មាន ៤ សញ្ជាតិគឺ :** ខ្មែរ ៩៧១នាក់ (ស្រី ៩៤នាក់),វៀតណាម ១៤ នាក់ (ស្រី ២ នាក់), ឡាវ ១នាក់, នីហ្សេរីយ៉ា ១នាក់ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

**ក្នុងចំនួនបទល្មើសគ្រឿងញៀនខាងលើ ៖**

- បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចនគរបាល ៤៦៨ ករណី** ឃាត់ខ្លួនជនសង្ស័យ **៨២៣ នាក់** (ស្រី ៧១នាក់)

- បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថ ៦៥ករណី** ឃាត់ខ្លួនជនសង្ស័យ **១៦៤ នាក់** (ស្រី ២៥នាក់)

- **វត្ថុតាងគ្រឿងញៀនចាប់យក :** មេតំហ្វេតាមីនក្រាមម្សៅ(ICE) ១$^{គ.ក្រ}$ ៣០២$^{ក្រាម}$ ៣៧០$^{មីលីក្រាម}$, មេតំហ្វេតាមីនគ្រាប់(WY) ៤៣៩$^{ក្រាម}$ ១០០$^{មីលីក្រាម}$, អ៊ិចស្តាស៊ី ៣០៧$^{ក្រាម}$, ១០០$^{មីលីក្រាម}$,ដើមកញ្ឆា ៧១៣$^{ក្រាម}$ ។

**(មេតំហ្វេតាមីន ICE និង WY សរុបរួម ២គ.ក្រ ០៤៩ ក្រាម ២៨៣ មីលីក្រាម)**

- ទ្រព្យសម្បត្តិសំខាន់ៗ ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន រួមមាន រថយន្ត ៤ គ្រឿង, ម៉ូតូ ១៥៩ គ្រឿង, ទូរស័ព្ទ ៤៦៩ គ្រឿង, ជញ្ជីង ២៩ គ្រឿង, ប្រាក់កម្ពុជា ៣.៩៦៩.៥០០ រៀល, ប្រាក់ថៃ ២០បាត, ប្រាក់អាមេរិក ២៤៥ ដុល្លារ, ប្រាក់វៀតណាម ២.៥២១.១០០ ដុង

- **ជនសង្ស័យចាប់តាមដីកា** មាន ២០ ដីកា ចាប់បានជនសង្ស័យ ១៨នាក់ (ស្រី០០នាក់) ។

### ៣.៣. លទ្ធផលកោសលវិច្ច័យលើសំណាកសង្ស័យជាគ្រឿងញៀន

- សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសលវិច័យ ក្នុងខែឧសភា ឆ្នាំ២០១៨ មាន**២៨៥ករណី** ស្មើនឹង **២៨៦សំណាក** ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន** មាន **២៨១ ករណី = ២៨១ សំណាក** (៩៨,២%) គឺ :
  - មេតំហ្វេតាមីនគ្រាប់ (WY) ០៣សំណាក = ១,០៥%
  - មេតំហ្វេតាមីនក្រាមម្សៅ (ICE) ២៧៣សំណាក = ៩៥,៤៥%
  - កេតាមីន ០១សំណាក = ០,៣៥%
  - កូកាអ៊ីន ០២សំណាក = ០,៦៩%
  - MDMA ០១សំណាក = ០,៣៥%
  - ហេរ៉ូអ៊ីន ០១សំណាក = ០,៣៥%
- **សំណាកអវិជ្ជមានសារធាតុញៀន ០៥ករណី = ០៥សំណាក** (១,៧៥%) ។

- បានផ្ដល់តេស្តរកសារជាតុញៀនក្នុងទឹកនោមចំនួន ៤៤៨០តេស្ត, និងស្រោមវេចខ្ចប់សំណាកសង្ស័យជាគ្រឿងញៀន ២០០ស្រោម ដល់អង្គភាពចំនួន ០២ មាន : អគ្គយនាកដ្ឋានពន្ធនាគារ, ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រួតពិនិត្យសារជាតុញៀន និងសារជាតុគីមីផ្សំក្នុងរាងទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ក្នុងខែឧសភា ឆ្នាំ២០១៨នេះ សរុបមាន **៦៧.៦៥០** គ.ក្រ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

- ថ្នាក់ដឹកនាំអគ្គលេខាធិការ អ.ជ.ប.គ.ញ. ៤រូប បានចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ កាលពីថ្ងៃទី៣០ ខែមេសា ដល់ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨ នៅខេត្តចាន់ថាបូរី ប្រទេសថៃ

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមសន្និសីទអាស៊ានឆ្នាំ២០១៨ ស្ដីពីកំណែទម្រង់យុត្តិធម៌ចំពោះអនីតិជន ដែលរៀបចំដោយអង្គការ (UNICEF) កាលពីថ្ងៃទី០២-០៤ ខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ប្រទេសថៃ

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១ រូប បានចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះ កម្ពុជា-វៀតណាម (JC) លើកទី១៦ ស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលរៀបចំដោយប្រទេសវៀតណាម កាលពីថ្ងៃទី១៦-១៨ ខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- ឯកឧត្តម អគ្គលេខាធិការ អ.ជ.ប.គ.ញ. និងសហការី ២រូប ចូលរួមក្នុងសន្និបាតថ្នាក់តំបន់អាស៊ានសមកាល សេដ្ឋកិច្ច និងសន្តិសុខអាស៊ានឆ្នាំ២០២៥ (ការជួញដូរគ្រឿងញៀន) ដែលរៀបចំដោយអង្គការ UNODC ពីថ្ងៃទី ០២-០៣ ខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ប្រទេសថៃ

- ឯកឧត្តម អគ្គលេខាធិការ អ.ជ.ប.គ.ញ. បានដឹកនាំប្រតិភូ ចូលរួមកិច្ចប្រជុំគណៈកម្មាធិការមន្ត្រីជាន់ខ្ពស់ បណ្ដាប្រទេសសមាជិកហត្ថលេខីនៃ MOU ទន្លេមេគង្គ ដែលរៀបចំដោយគណៈកម្មាធិការកណ្ដាល

ត្រួតពិនិត្យ គ្រឿងញៀនមីយ៉ាន់ម៉ា (CCDAC) ពីថ្ងៃទី ២១-២៥ ខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងណៃពិដោរ សាធារណៈរដ្ឋ សហភាពមីយ៉ាន់ម៉ា ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

- ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១រូប ចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីណែនាំពីគោលការណ៍រៀបចំធាតុចូលសម្រាប់ពាក់ព័ន្ធបញ្ហាគ្រឿងញៀន និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០១៩-២០២៣ ដែលរៀបចំដោយក្រសួងផែនការ កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ នៅសណ្ឋាគារភ្នំពេញ
- បន្តជំរុញការអនុវត្តសកម្មភាពនៃផែនការភូមិ ស គ្មានគ្រឿងញៀន
- បន្តរៀបចំខ្លឹមសារសេចក្ដីព្រាងទាក់ទងមាត្រាមួយចំនួន ដែលបានចែងនៅក្នុងច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ពាក់ព័ន្ធនឹងការរឹបអូសទ្រព្យ សម្បត្តិដែលជាផលបានមកពីបទល្មើសគ្រឿងញៀន ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១៨

ដើម្បីអនុវត្តបន្តឱ្យមានប្រសិទ្ធភាព នូវផែនការជាតិស្ដីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៨ ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ (ឆ្នាំ២០១៨) អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានដាក់ចេញនូវផែនការសកម្មភាពអនុវត្តទិសដៅការងារ សម្រាប់**ខែមិថុនា ឆ្នាំ ២០១៨** ដូចខាងក្រោម ៖

**១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន**

១.១. ត្រៀមរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ។

១.២. បន្តកិច្ចសហការជាមួយក្រសួងទេសចរណ៍, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន, សភាពការណ៍គ្រឿងញៀន, ចំណេះដឹងទូទៅពីគ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមតំបន់ទេសចរណ៍របស់រាជធានី-ខេត្ត គ្រឹះស្ថានសិក្សា និងបណ្ដារោងចក្រនានា ។

១.៣. ត្រៀមចូលរួមផ្ដល់កិច្ចសម្ភាសន៍ ក្រោមប្រធានបទស្ដីពីលទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ របស់រាជរដ្ឋាភិបាល នៅស្ថានីយទូរទស្សន៍ហង្សមាស ។

១.៤. បន្តសហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី. អញ្ជើញតំណាងអគ្គនាយកនៃអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ ចូលរួមផ្ដល់ កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងតំណាងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ចូលរួមផ្ដល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច ក្រោមប្រធានបទ ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣។

១.៥. បន្តសហការជាមួយស្ថានីយទូរទស្សន៍បាយ័ន ហង្សមាស និងNICETV ដើម្បីធ្វើការផ្សព្វផ្សាយពីការងារដែលទាក់ទងនឹងបញ្ហាគ្រឿងញៀន។

១.៦. បន្តសហការជាមួយក្រុមហ៊ុន HD &S Group Co.,LTD បញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីប្រគំតន្ត្រីទេសចរណ៍គ្មានគ្រឿងញៀន ។

១.៧. បន្តចលនាឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៨. បន្តបោះពុម្ពខិត្តប័ណ្ណអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន សម្រាប់ផ្សព្វផ្សាយអប់រំទៅ

លើក្រុមគោលដៅជាសិស្សានុសិស្ស ។

១.៩. បន្តជំរុញនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ការងារផ្សព្វផ្សាយអប់រំជាមួយវិស័យឯកជន និងក្រុមហ៊ុន ។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន**

២.១. ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីព្យាបាលជាសកលសម្រាប់អ្នកញៀនគ្រឿងញៀន ដែលរៀបចំដោយក្រសួងសុខភាពសាធារណៈថៃ នៅប្រទេសថៃ ។

២.២. បន្តការចូលរួមប្រមូលទិន្នន័យការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ការប្រព្រឹត្តផ្លូវភេទ និងការប៉ាន់ប្រមាណរកចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅប្រទេសកម្ពុជាឆ្នាំ២០១៧ ។

២.៣. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្ម ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព ។

២.៤. បន្តការកែសម្រួលនិងពង្រឹងសមត្ថភាព គុណភាព នៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២.៥. បន្តដំណើរការសាងសង់មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

២.៦. បន្តជំរុញការរៀបចំសេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន ដែលជាទណ្ឌិតនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ ។

២.៧. បន្តចលនា និងផ្តល់ការសម្របសម្រួលឱ្យមានការចូលរួមពីវិស័យឯកជន លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់**

៣.១. បន្តកិច្ចសហការជាមួយអង្គការ UNODC ដើម្បីរៀបចំបង្កើតការិយាល័យទំនាក់ទំនង (**BLO**) ថ្មីកម្ពុជា-វៀតណាម ចំនួន ២ នៅច្រកទ្វារព្រំដែនអន្តរជាតិអូយ៉ាដាវ (ខេត្តរតនគិរី) និងច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក (ខេត្តកំពត) ។

៣.២. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២រូប ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតបទល្មើសតាមប្រព័ន្ធអនឡាញសម្រាប់មន្ត្រីអនុវត្តច្បាប់ ដែលរៀបចំដោយអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) នៅខេត្តសៀមរាប ។

៣.៣. ត្រៀមជួបពិភាក្សាការងារជាមួយសមាជិកដែលពាក់ព័ន្ធអំពីការអនុវត្តគម្រោង PATROL នៅតាមព្រំដែននៃច្រកទ្វារនីមួយៗ ។

៣.៤. បន្តបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ស្តីពីគ្រឿងញៀន តាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (e-Learning) និងតាមប្រព័ន្ធកុំព្យូទ័រ (CBT) ។

៣.៥. ជំរុញការបង្កើតក្រុមការងារត្រួតពិនិត្យគ្រឿងញៀន តាមអាកាសយានដ្ឋានអន្តរជាតិ និងកំពង់ផែអន្តរជាតិ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ**

៤.១. បន្តការចងក្រងព័ត៌មានពាក់ព័ន្ធនឹងសារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

៤.២. បន្តចូលរួមជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងទំនិញគ្រោះថ្នាក់។

៤.៣. បន្តរៀបចំកិច្ចប្រជុំក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំឱ្យបានទៀងទាត់។

៤.៤. ត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន**

៥.១. ចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ១រូប និងសហការី ២រូប ត្រៀមចូលរួមក្នុងកិច្ចប្រជុំ និងទស្សនកិច្ចសិក្សាស្តីពីភូមិស គ្មានគ្រឿងញៀន រវាងថៃ កម្ពុជា និងថៃ-ឡាវ ពីថ្ងៃទី១៨ ដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ នៅខេត្តអ៊ូប៊ុនរ៉ាឆាថានី ប្រទេសថៃ ។

៥.២. ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ៤រូប ត្រៀមចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី Universal Treatment Curriculum for Substance Use Disorders (UTC) ពីថ្ងៃទី១១ ដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ នៅប្រទេសថៃ ។

៥.៣. បន្តអនុវត្តផែនការសកម្មភាព ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី កម្ពុជា-ថៃ ឆ្នាំ២០១៧-២០១៨ ។

៥.៤. បន្តអនុវត្តផែនការសកម្មភាពគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់កម្ពុជា ថៃ ឡាវ រយៈពេល ២ឆ្នាំ (២០១៧ -២០១៨) ។

៥.៥. ត្រៀមទៅចូលរួមកិច្ចប្រជុំត្រីភាគី-ទ្វេភាគី កម្ពុជា-ឡាវ-វៀតណាម ដែលនឹងប្រារព្ធនៅប្រទេសឡាវ ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

៦.១. ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១រូប ត្រៀមចូលរួមក្នុងវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ ស្តីពីការអង្កេតគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន នៃគម្រោង PATROL នៅខេត្តកំពត ។

៦.២. ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រៀមសម្របសម្រួលក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសស៊ើបអង្កេតទីតាំងកើតហេតុ និង បច្ចេកទេសស៊ើបអង្កេតដទៃទៀតពាក់ព័ន្ធនឹងបទល្មើសសត្វព្រៃ ពីថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ នៅទីក្រុងភ្នំពេញ ដែលរៀបចំដោយអង្គការ UNODC ។

៦.៣. ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ២ .ញ.គ.ប.ជ.រូប ត្រៀមចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការលុបបំបាត់ និងការស៊ើបអង្កេតបទល្មើសគ្រឿងញៀន ពីថ្ងៃទី១៧ ខែមិថុនា ដល់ថ្ងៃទី៧ ខែកក្កដាឆ្នាំ២០១៨ នៅប្រទេសកូរ៉េ ដែលសហការរៀបចំដោយ SPO និង KOICA ។

៦.៤. ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចំនួន៥រូប ត្រៀមចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យគ្រឿងញៀនសម្រាប់មន្ត្រីអនុវត្តច្បាប់ ពីថ្ងៃទី២៣ ខែមិថុនា ដល់ថ្ងៃទី៧ ខែកក្កដាឆ្នាំ២០១៨ នៅប្រទេសចិន ។

៦.៥. បន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី អង្គការ**UNODC** បណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

៧.១. ត្រៀមផ្សព្វផ្សាយ ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.២. បន្តណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាពសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

៧.៣. បន្តការចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ (០១ ខែមករា-៣១ ខែធ្នូ ឆ្នាំ២០១៨) ។

៧.៤. បន្តការរៀបចំការកែសម្រួលមាត្រាមួយចំនួន ពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលបានមកពីបទល្មើសគ្រឿងញៀន ដែលមានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧.៥. ត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីពិភាក្សាអំពីការដាក់បញ្ចូលរុក្ខជាតិ khat (ខាត) ទៅក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អគ្គលេខាធិការ**

**នាយឧត្តមសេនីយ៍ មាស_វិរិទ្ធ**

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដាក់ អនុប្រធាន អ.ជ.ប.គ.ញ.
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.

  " ដើម្បីជូនជ្រាប "
- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

  " ដើម្បីមុខការ "
- ឯកសារ-កាលប្បវត្តិ